**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

70th Anniversary of Diplomatic Relations between CAMBODIA - JAPAN

ថ្ងៃព្រហស្បតិ៍ ៦រោច ខែបុស្ស ឆ្នាំខាល

ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មានរួម

## ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងកំណត់ហេតុនៃកិច្ចពិភាក្សាស្តីពី "គម្រោងរៀបចំផែនការអភិវឌ្ឍន៍វិស័យទឹកស្អាតទីប្រជុំជន"

នារសៀលថ្ងៃទី១២ ខែមករា ឆ្នាំ២០២៣ នៅទីស្តីការក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងកំណត់ហេតុនៃកិច្ចពិភាក្សាស្តីពី **គម្រោងរៀបចំផែនការអភិវឌ្ឍន៍វិស័យទឹកស្អាតទីប្រជុំជន** ក្រោមអធិបតីភាព **ឯ.ឧ អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង លោកស្រី **KAMEI Haruko** ប្រធានតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ប្រចាំនៅកម្ពុជា។

គម្រោងនេះ គឺជាគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសទី ៥ ក្នុងវិស័យទឹកស្អាតចាប់ពីឆ្នាំ ២០០៣។ គោលដៅរំពឹងទុករបស់គម្រោង គឺដើម្បីលើកកម្ពស់សមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធរបស់ក្រសួង និងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការរៀបចំបទបញ្ញត្តិ និងការគ្រប់គ្រងអង្គភាពទឹកស្អាតទីប្រជុំជន តាមរយៈការរៀបចំនូវគោលការណ៍ណែនាំអំពីការអភិវឌ្ឍន៍វិស័យទឹកស្អាតតាមទីប្រជុំជន គំរូផែនការអភិវឌ្ឍន៍ទឹកស្អាតនៅទីប្រជុំជនថ្នាក់ខេត្ត និងគំរូផែនការមេសម្រាប់អង្គភាពទឹកស្អាតសាធារណៈ។ គម្រោងនេះនឹងរួមចំណែក ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹកស្អាត ដែលមានគុណភាព សុវត្ថិភាព និរន្តរភាព និងតម្លៃសមរម្យនៅក្នុងប្រទេសកម្ពុជា។

គម្រោងនេះក៏នឹងជួយដល់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការរៀបចំគោលការណ៍ណែនាំ និងផែនការអភិវឌ្ឍន៍វិស័យទឹកស្អាត តាមរយៈការកសាងសមត្ថភាពជាបន្តបន្ទាប់ដល់មន្ត្រីជំនាញពាក់ព័ន្ធរបស់ក្រសួង និងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ផ្អែកលើឯកសារកិច្ចព្រៀងកំណត់ហេតុនៃកិច្ចពិភាក្សា គម្រោងនេះរំពឹងថានឹងត្រូវចាប់ផ្ដើមអនុវត្តនៅពាក់កណ្ដាលឆ្នាំ២០២៣ ខាងមុខនេះ ដោយមានគោលបំណងរៀបចំគោលការណ៍ណែនាំអំពីការអភិវឌ្ឍន៍វិស័យទឹកស្អាតទីប្រជុំជន គំរូផែនការអភិវឌ្ឍន៍ទឹកស្អាតទីប្រជុំជនថ្នាក់ខេត្ត និងគំរូផែនការមេសម្រាប់អង្គភាពទឹកស្អាតសាធារណៈនៅខេត្តគោលដៅ។ សកម្មភាពរបស់គម្រោងក៏នឹងរួមបញ្ចូលទាំងការកសាងសមត្ថភាពមន្ត្រីជំនាញពាក់ព័ន្ធរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិង នវានុវត្តន៍ ផងដែរ។

JICA គឺជាដៃគូអភិវឌ្ឍមួយដ៏យូរអង្វែងមួយក្នុងវិស័យទឹកស្អាតនៅកម្ពុជា ដែលតាមរយៈ JICA រដ្ឋាភិបាលជប៉ុនប្ដេជ្ញាធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្ររយៈពេលយូរជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដើម្បីសម្រេចឱ្យបាននូវការទទួលបានទឹកស្អាត និងមានសុវត្ថិភាពសម្រាប់ប្រជាជនកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

- *ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍៖*
  - ***ឯ.ឧ តន់ សុខជា*** *អគ្គនាយកនៃអគ្គនាយកដ្ឋានទឹកស្អាត ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈអ៊ីម៉ែល tan.sokchea@gmail.com ឬ ទូរស័ព្ទ 012 879 738.*
  - ***ឯ.ឧ បណ្ឌិត ស្រេង សុខវុង្ស*** *ប្រធាននាយកដ្ឋានបច្ចេកទេសនិងគ្រប់គ្រងគម្រោង នៃអគ្គនាយកដ្ឋានទឹកស្អាត តាមរយៈអ៊ីម៉ែល sokvung@gmail.com ឬ ទូរស័ព្ទ077 891 121*
- *ការិយាល័យ JICA ប្រចាំកម្ពុជា៖*
  - ***លោក យ៉ោក សេងអាន*** *តាមរយៈអ៊ីម៉ែល Youk-SengAn@jica.go.jp*

*******************